ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តតាកែវ

សាលក្រមលេខ : ២១ "ក"

ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨

## នាមនាមព្រះរាជាណាចក្រខ្មែរ

## តុលាការខេត្តតាកែវ

បានបើកសវនាការជាសាធារណៈ នៅតុលាការខេត្ត តាកែវ នាថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨

ដោយមានសមាសភាពដូចខាងក្រោម :

### ចៅក្រមជំនុំជម្រះ

លោក [redacted] ប្រធានតុលាការខេត្តតាកែវ

### ក្រឡាបញ្ជី

លោក [redacted]

ដើម្បីជំនុំជម្រះរឿងរដ្ឋប្បវេណីលេខ : ១៤៨ ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលមាន :

ដើមចោទឈ្មោះ [redacted] នន់ ភេទ ប្រុស អាយុ ៥៩ ឆ្នាំ មុខរបរ គ្រូបង្រៀន ទីលំនៅសព្វថ្ងៃនៅភូមិ ថ្នល ឃុំ គោកពោធិ៍ ស្រុកបូរីជលសារ ខេត្ត តាកែវ ឪពុកឈ្មោះ សាន់ "ស" ម្តាយឈ្មោះ អ៊ិន "ស" ប្រពន្ធឈ្មោះ [redacted] ស្រេន និង ចុងចម្លើយឈ្មោះ [redacted] ស្រេន ភេទ ស្រី អាយុ ៥៤ ឆ្នាំ មុខរបរ លក់គ្រឿងសំណង់ ទីលំនៅសព្វថ្ងៃនៅ ភូមិ ថ្នល ឃុំ គោកពោធិ៍ ស្រុក បូរីជលសារ ខេត្ត តាកែវ ឪពុកឈ្មោះ [redacted] រ៉ា "ស" ម្តាយឈ្មោះ សៀក "ស" ប្តី ឈ្មោះ [redacted] នន់ ។

## អង្គហេតុមានដូចតទៅ

តាមពាក្យបណ្តឹងរបស់ឈ្មោះ [redacted] នន់ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៧ ថាខ្លួនបានរៀបការជាមួយ នាង [redacted] ស្រេន តាំងពីឆ្នាំ ១៩៨៨ គ្មានកូននឹងគ្នាទេ មានតែកូនដើមរៀង១ខ្លួន ។ ទ្រព្យសម្បត្តិរួមមានផ្ទះ ដី និង ឥវ៉ាន់លក់ ដូរគ្រឿងសំណង់ ប៉ុន្តែរយៈពេលជិត ១ ឆ្នាំ ប្រពន្ធខ្លួនមិនបានបំពេញតួនាទីជាមេផ្ទះ គេងប្រវ័ញ្ចទ្រព្យសម្បត្តិ ចង់កាន់ កាប់ម្នាក់ឯង ។

៤៩៤



Scanned with CamScanner

## ចំណុចពិភាក្សាពេលត្រៀមទាញហេតុផល

ដើមចោទប្តឹងសុំលែងលះ និងសុំបែងចែកទ្រព្យសម្បត្តិរួម ឯចុងចំលើយមិនព្រមលែងលះ មិនព្រមបែងចែកទ្រព្យសម្បត្តិរួម ។

## ការទាញហេតុផលផ្ទាល់មាត់

-ឈ្មោះ [redacted] ធន់ ដើមចោទបានចូលមកហើយ បានថ្លែងអោយការណ៍ថា : ខ្លួននៅតែប្តឹងសុំលែងលះពីនាង [redacted] ស្រេន និង សុំបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នា ដោយហេតុថាខ្លួនបានរៀបការតាំពីឆ្នាំ ១៩៨៨ រហូតមកដល់សព្វថ្ងៃគ្មានកូននឹងគ្នាទេ តែមានកូនដើមរៀង១ខ្លួន ។ ឯទ្រព្យសម្បត្តិរួមដែលរកស៊ីរួមគ្នាកន្លងមកមានដីស្រែប្រាំង ១១,៥០ ហិកតា ឯកភាពគ្នាលក់ ០២ ហិកតា សងបំណុលអេស៊ីលីដា ប្រពន្ធលក់ ៣,៥០ ហិកតា ពុំមានការឯកភាពពីខ្លួនទេ តែខ្លួនក៏មិនទាមទារដែរ នៅសល់សព្វថ្ងៃចំនួន ០៦ ហិកតា ផ្ទះលក់គ្រឿងសំណង់ ០១ កន្លែងនៅលើប្រពន្ធកាន់កាប់ ដីនៅជាប់ផ្សារថ្មស ផ្ទះនៅមុខស្ថានីយ៍បូមទឹកឃុំគោកពោធិ៍កាត់បំណុលពីគេ ដីលំនៅដ្ឋាន ០១ កន្លែងទំហំ 10m x 65m មានកូនផ្ទះនៅជាប់ប្រឡាយ ០១ មុខស្ថានីយ៍បូមទឹកថ្មស ខ្លួនស្នាក់នៅសព្វថ្ងៃគ្មានជាប់បំណុលគេទេ ។ ពេលនេះខ្លួនសុំអោយតុលាការសំរេចអោយខ្លួនបានលែងលះតាមផ្លូវច្បាប់ សុំកាន់កាប់ដីសង់លំនៅដ្ឋានទំហំ 10m x 60m ដែលមានកូនផ្ទះមួយ សុំកាន់កាប់ផ្ទះនៅមុខស្ថានីយ៍បូមទឹកឃុំគោកពោធិ៍ ដីស្រែប្រាំងដែលនៅសល់ ០៦ ហិកតា សុំតុលាការបែងចែកស្មើគ្នា ក្រៅពីនេះខ្លួនមិនទាមទារអ្វីទៀតទេ ។

-ក្រឡាបញ្ជីអានចំលើយនាង [redacted] ស្រេន នៅពេលផ្សះផ្សា និង នៅពេលត្រៀមទាញហេតុផល ។

-ប្រឡាបញ្ជីអានចំលើយសាក្សី

## តុលាការយល់ឃើញថា

-ដើមចោទ និង ចុងចំលើយពិតជាប្តីប្រពន្ធនឹងគ្នាតាំងពីឆ្នាំ ១៩៨៨ រហូតមកដល់សព្វថ្ងៃ តែពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ដូចលិខិតបញ្ជាក់អាពាហ៍ពិពាហ៍លេខ ៩៣៥.០៧ ត.ព ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៧ របស់មេឃុំគោកពោធិ៍ ស្រុកបូរីជលសារ ខេត្ត តាកែវ ។

=ដើមចោទប្តឹងសុំលែងលះប្រពន្ធ សុំបែងចែកទ្រព្យសម្បត្តិរួម ឯចុងចំលើយមិនព្រមលែងលះ និង មិនសុខចិត្តបែងចែកទ្រព្យសម្បត្តិរួម តុលាការពិចារណាសំរេចតាមច្បាប់ ។

-គូភាគីឯកភាពលើការប្រកាសទ្រព្យសម្បត្តិរួម ។

២៩៣



Scanned with CamScanner

## ហេតុដូច្នេះតុលាការសំរេច

១. ទទួលស្គាល់បណ្តឹងទាមទាររបស់ដើមចោទឈ្មោះ [redacted] ទន់ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៧ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ និង គតិច្បាប់ ។

២. ទទួលស្គាល់លិខិតបញ្ជាក់អាពាហ៍ពិពាហ៍លេខ ៩៣៥.០៧ ត.ព ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៧ របស់មេឃុំ គោកពោធិ៍ ស្រុក បូរីជលសារ ខេត្ត តាកែវ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣. អោយឈ្មោះ [redacted] ទន់ (ប្តី) និង [redacted] អ៊ុន ស្រេន (ប្រពន្ធ) បញ្ឈប់ការរស់នៅបែប អនីតិសង្វាស នឹងគ្នាចាប់ពី ពេលនេះតទៅ ដោយដាក់កំហុសខាងប្តី តាមមាត្រា ៣៩ ចំណុចទី ៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ។

៤. ទ្រព្យសម្បត្តិរួមមាន :

- ផ្ទះលក់គ្រឿងសំណង់ ០១ កន្លែង ដីសំរាប់សង់លំនៅដ្ឋាន ០១ កន្លែងស្ថិតនៅជាប់ផ្សារថ្មស ឃុំ គោកពោធិ៍ និង ដីស្រែប្រាំង ០៣ ហិកតា ប្រគល់អោយនាង [redacted] ស្រេន ជាអ្នកគ្រប់គ្រង ។

- ដីទំហំ 10m x 65m (មានកូនផ្ទះមួយជាប់ប្រឡាយ ០១ មុខស្ថានីយ៍បូមទឹកថ្មស)ផ្ទះមួយនៅមុខស្ថានីយ៍បូមទឹកឃុំគោកពោធិ៍ និង ដីស្រែប្រាំងចំនួន ០៣ ហិកតា ប្រគល់អោយឈ្មោះ [redacted] ទន់ ជាអ្នកគ្រប់គ្រង ។

៥. រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ៧០០០ រៀល ដែលដើមចោទបានបង់ទុករួចហើយ ។

៦. សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចំលើយ តែទុកដូចជាចំពោះមុខបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ

ហត្ថលេខា និង ត្រា

[redacted]

ចៅក្រមជំនុំជំរះ

ហត្ថលេខា និង ត្រា

[redacted]

---

បានឃើញ

ចៅក្រមជំនុំជំរះ

បានចំលងចេញត្រឹមត្រូវតាមច្បាប់ដើម

តាកែវ.ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៨

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner